# សេចក្តីសម្រេច
# បង្កើតមណ្ឌល
# ទទួលពលករកំរៀង



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ១១០/២១ គ.ជ.វ

សេចក្ដីសម្រេច
ស្ដីពី
ការបង្កើតមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ប្រការ ២._

មណ្ឌលទទួលពលករកំរៀង មានតួនាទី៖

- ជាមណ្ឌលទទួលសម្របសម្រួល ផ្តល់សេវាចាំបាច់បន្ទាន់ដល់ពលករទេសន្តរប្រវេសន៍ ដែលត្រូវបានបញ្ជូនត្រលប់ដោយអាជ្ញាធរបរទេស ឬវិលត្រលប់ពីបរទេស ឬពលករ ដែលរងគ្រោះ និងងាយរងគ្រោះ
- ជាមណ្ឌលព័ត៌មានអំពីអត្តសញ្ញាណពលករ ព័ត៌មានពាក់ព័ន្ធនឹងសុវត្ថិភាពទេសន្តរប្រវេសន៍
- ជាកន្លែងអប់រំ ផ្តល់ប្រឹក្សាអំពីជម្រើសសមស្របក្នុងការរស់នៅ ការដោះស្រាយបញ្ហា ការងារ មុខរបរក្រៅពីការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន
- ផ្តល់សេវាចាំបាច់ បន្ទាន់ ជាពិសេសដល់ជនទេសន្តរប្រវេសន៍ជាស្ត្រី (មានផ្ទៃពោះ កូនតូច) កុមារគ្មានទីពឹង និងមនុស្សចាស់ និងសេវាបញ្ជូន
- ជាមណ្ឌលមេត្រីភាពដែលប្រជាពលរដ្ឋក្នុងតំបន់ និងប្រជាពលរដ្ឋឆ្លងកាត់ អាចទំនាក់ទំនងស្វែងរក និងទទួលបានព័ត៌មាន និងចំណេះដឹងផ្សេងៗ អំពីការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាពស្របច្បាប់ ព្រមទាំងទម្រង់ផ្សេងៗនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ច
- ជាមណ្ឌលដែលផ្តល់ផលប្រយោជន៍ ជាពហុវិស័យដល់ពលករទេសន្តរប្រវេសន៍ និងអនុញ្ញាតឱ្យគ្រប់ភាគីពាក់ព័ន្ធ ស្នើសុំកិច្ចសហការដើម្បីចូលរួមប្រើប្រាស់មណ្ឌលនេះក្នុងការចែករំលែកនូវបទពិសោធន៍ ចំណេះដឹង និងធ្វើសហប្រតិបត្តិការក្នុងគោលដៅសុវត្ថិភាពទេសន្តរប្រវេសន៍ និងប្រឆាំងការជួញដូរមនុស្ស សម្រាប់ពលរដ្ឋទាំងនៅក្នុង និងក្រៅស្រុក ឬខេត្ត ។

- **ប្រការ ៣.**_

មណ្ឌលទទួលពលករកំរៀង ត្រូវបានទ្រទ្រង់ដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ | ប្រធាន |
| ២. អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| ៣. អគ្គលេខាធិការរង ទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | សមាជិក |
| ៤. អភិបាល ឬអភិបាលរងខេត្តបាត់ដំបង ទទួលបន្ទុក ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ | សមាជិក |
| ៥. ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបាត់ដំបង | សមាជិក |
| ៦. ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបាត់ដំបង | សមាជិក |
| ៧. ប្រធានមន្ទីរកិច្ចការនារី ខេត្តបាត់ដំបង | សមាជិក |
| ៨. ប្រធានមន្ទីរសុខាភិបាល ខេត្តបាត់ដំបង | សមាជិក |
| ៩. ស្នងការរងទទួលបន្ទុកផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | សមាជិក |
| ១០. អភិបាលស្រុកកំរៀង ខេត្តបាត់ដំបង | សមាជិក |
| ១១. ប្រធានអង្គការការីតាសស្វីស | សមាជិក |
| ១២. ដៃគូសហការដទៃទៀត តាមការចាំបាច់ | សមាជិក |

**ប្រការ ៤._**

ក្រុមប្រឹក្សាភិបាលមានតួនាទី៖

- ទទួលខុសត្រូវក្នុងការគាំទ្រ រៀបចំ និងដំណើរការមណ្ឌល ដោយផ្តល់នូវបច្ចេកទេស ការប្រឹក្សាយោបល់ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រង និងអភិវឌ្ឍមណ្ឌល
- ផ្តល់ការយល់ដឹងផ្នែកច្បាប់ គោលនយោបាយ បទដ្ឋាន និងនីតិវិធីចាំបាច់មួយចំនួន ដែលបម្រើឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបនៃការផ្តល់សេវាផ្សេងៗ ស្របតាមមុខងាររបស់មណ្ឌល
- តាមដាន និងផ្តល់ប្រឹក្សាយោបល់ដល់អ្នកទទួលខុសត្រូវមណ្ឌល អំពីរបៀបរបបការងារ ការងារទំនាក់ទំនងសម្របសម្រួល ការអភិវឌ្ឍ និងការថែទាំមណ្ឌល
- ប្រមូលព័ត៌មាន ទិន្នន័យ ចងក្រង វិភាគ និងលើកវិធានការ ដើម្បីអនុវត្តឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ឆ្លើយតបទៅនឹងគោលដៅ និងគោលបំណងនៃមណ្ឌល ។

**ប្រការ ៥._**

ដើម្បីធានានិរន្តរភាពការងារ ក្នុងការប្រើប្រាស់មណ្ឌលទទួលពលករកំរៀងឱ្យចំទិសដៅ ប្រកបដោយប្រសិទ្ធភាព និងទទួលបានប្រសិទ្ធផល ការដឹកនាំ គ្រប់គ្រង និងប្រតិបត្តិការ ត្រូវបានរៀបចំ និងប្រព្រឹត្តទៅដូចខាងក្រោម៖

**ក. ការងារដឹកនាំនៅថ្នាក់ស្រុក៖**

១. អភិបាលស្រុកកំរៀង ជាប្រធាន មានភារកិច្ចជួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តបាត់ដំបង ដឹកនាំ ចង្អុលណែនាំតម្រង់ទិសពិនិត្យ ចុះហត្ថលេខាលើរបាយការណ៍ ដាក់ចេញគោលការណ៍អនុវត្ត ស្នើមតិដឹកនាំពី គ.ជ.ប.ជ រដ្ឋបាលខេត្ត តាមការចាំបាច់ សម្រេចតែងតាំងមន្ត្រី កោះប្រជុំ សម្រេចការងារ ដោះស្រាយសំណូមពរ ភាពប្រឈម ទំនាក់ទំនងដៃគូសប្បុរសជន ស្វែងរកមូលនិធិ និងលើកគម្រោងថវិកាជាតិ ដើម្បីបន្តឧបត្ថម្ភគាំទ្រដំណើរការ ធានានិរន្តរភាពការងារ។ សម្របសម្រួល និងផ្តល់លទ្ធភាពឱ្យអង្គការដែលបានស្នើសុំកិច្ចសហការអនុស្សរណៈនៃការយោគយល់គ្នា (MOU) បានធ្វើការងារជាមួយមណ្ឌលតាមការឯកភាព ។

២. អភិបាលរងស្រុកកំរៀង ០១ (មួយ)រូប ជាអនុប្រធាន មានភារកិច្ចជួយប្រធានក្នុងការផ្តល់ប្រឹក្សាតាមដាន ត្រួតពិនិត្យ រៀបចំផែនការការងារ វិន័យ បទបញ្ជាផ្ទៃក្នុង ពិនិត្យរបាយការណ៍មុនផ្ញើជូនប្រធាន ពិនិត្យសម្រេច និងស្នើសុំយោបល់ប្រធាន ដោះស្រាយភាពប្រឈមនានា ។

ខ. មន្ត្រីប្រចាំការ គ្រប់គ្រង និងប្រតិបត្តិ៖

១. អ្នកគ្រប់គ្រងមណ្ឌល ០១ (មួយ)រូប ៖ ជាមន្ត្រីប្រចាំការមានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រង និងអភិវឌ្ឍមណ្ឌល ការងាររដ្ឋបាល កត់ត្រាបញ្ជីការ ធ្វើលិខិតរដ្ឋបាល(តាមឋានានុក្រម) ចាត់ចែងដោះស្រាយការងារប្រចាំថ្ងៃ ចាត់ចែងទុកដាក់ធ្វើបញ្ជីចេញចូល បែងចែកសម្ភារប្រើប្រាស់ គ្រប់គ្រងមន្ត្រី បុគ្គលិក ចាត់តាំងមន្ត្រីបំពេញការងារ ណែនាំ ដាស់តឿន រៀបចំប្រតិទិនការងារ រៀបចំវិន័យ បទបញ្ជាផ្ទៃក្នុង ការងារសន្តិសុខ ដាក់វិធានការថែទាំ សម្អាតមណ្ឌល ទំនាក់ទំនងសម្របសម្រួល សហការជាមួយដៃគូការងារពាក់ព័ន្ធ



ពិនិត្យ ចុះហត្ថលេខាលើសំណើ របាយការណ៍ ដែលត្រូវធ្វើទៅប្រធាន ឬលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបាត់ដំបង ឬអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។

២. មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ៖ ជាមន្ត្រីជំនួយការគ្រប់គ្រងមណ្ឌលមានភារកិច្ចធ្វើការងាររដ្ឋបាល និងហិរញ្ញវត្ថុ ផ្គត់ផ្គង់ ជួយការងារបុគ្គលិក ធ្វើបញ្ជីវត្ថុមាន ការងារបញ្ជីសារពើភ័ណ្ឌ ការងារហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំ ទំនាក់ទំនង សម្របសម្រួលទទួលភ្ញៀវ ការងារសហការជាមួយដៃគូ និងត្រួតពិនិត្យការងារអនាម័យក្នុងមណ្ឌល បូកសរុបរបាយការណ៍ប្រចាំថ្ងៃ ខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំ ដាក់ជូនអ្នកគ្រប់គ្រង និងប្រធានពិនិត្យ ចុះហត្ថលេខា មុននឹងបញ្ជូនទៅលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបាត់ដំបង និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

៣. មន្ត្រីស្រាវជ្រាវ និងអប់រំផ្សព្វផ្សាយ មានភារកិច្ច៖

- ទទួលពលករ ចុះបញ្ជី បញ្ចូលទិន្នន័យព័ត៌មានផ្ទាល់ខ្លួនពលករ តាមរយៈការសម្ភាស កំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងភាពប្រឈមផ្សេងៗទៀត
- ស្នើសុំយោបល់ប្រធាន និង/ឬទំនាក់ទំនងជាមួយអង្គភាព ស្ថាប័ន អង្គការពាក់ព័ន្ធ ដើម្បីសហការ ផ្តល់សេវា និងអនុវត្តតាមគោលការណ៍ និងនីតិវិធីបញ្ជូន និងផ្តល់សេវាសមស្រប រួមមាន ការដោះស្រាយមធ្យោបាយធ្វើដំណើរ ការស្នាក់នៅបណ្តោះអាសន្ន ការបញ្ជូនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដើម្បីពិនិត្យព្យាបាល ឬសង្គ្រោះបន្ទាន់ ផ្តល់ការឧបត្ថម្ភ តម្រូវការចាំបាច់ បន្ទាន់ចាំបាច់ សម្រាប់ក្មេង ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូចតាមខ្លួន អ្នកជំងឺជាដើម
- ផ្តល់ព័ត៌មាន ប្រឹក្សាយោបល់ និងអប់រំដល់ពលករ ពលការិនីរងគ្រោះ ឬងាយរងគ្រោះ ពាក់ព័ន្ធនឹងសុវត្ថិភាពនៃទេសន្តរប្រវេសន៍ ការងារអំពើជួញដូរមនុស្ស ជម្រើសក្នុងការរស់នៅ ទីផ្សារការងារ និងព័ត៌មានចាំបាច់ដទៃទៀត

- រៀបចំប្រព័ន្ធដើម្បីទំនាក់ទំនងទៅរាជធានី-ខេត្តពាក់ព័ន្ធ សម្របសម្រួលទទួល និងគ្រប់គ្រងពលករ ពលការិនី ដែលត្រូវបានបញ្ជូនត្រលប់ឱ្យដល់សហគមន៍
- ទំនាក់ទំនងចុះសិក្សាស្ថានភាពប្រឈមរបស់ប្រជាពលរដ្ឋ ធ្វើការអប់រំប្រជាពលរដ្ឋតាមសហគមន៍ ស្តីពីផលវិបាកនៃទេសន្តរប្រវេសន៍ប្រថុយប្រថាន ខុសច្បាប់ និងផ្តល់ជម្រើសសមស្របផ្សេងទៀត
- ប្រមូលចងក្រងសេវាកម្ម លេខទូរស័ព្ទទំនាក់ទំនងជាមួយមន្ទីរ ស្ថាប័ន អង្គភាពពាក់ព័ន្ធ នឹងការផ្តល់សេវាជួយជនរងគ្រោះ និងជនទេសន្តរប្រវេសន៍ដែលមានបញ្ហា និងដែលត្រូវវិលត្រលប់ទៅសហគមន៍មូលដ្ឋានវិញ
- ចុះស្រាវជ្រាវ អប់រំ ផ្សព្វផ្សាយ តាមគោលដៅ មណ្ឌលចត្តាឡីស័ក ភូមិឃុំ សហគមន៍
- ចុះតាមដាន វាយតម្លៃការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថរបស់ពលរដ្ឋក្នុងសហគមន៍
- ទំនាក់ទំនងសហការជាមួយអាជ្ញាធរ សមត្ថកិច្ច ការិយាល័យ ឬមន្ទីរសង្គមកិច្ច ការិយាល័យ ឬមន្ទីរការងារ មណ្ឌលសុខភាព ការិយាល័យ គ.ក.ន.ក ស្រុក អង្គការដៃគូពាក់ព័ន្ធ ដើម្បីដោះស្រាយ ការងារ និងផ្តល់សេវាសមស្រប
- ទទួលការបណ្តុះបណ្តាល ចូលរួមកិច្ចប្រជុំ សិក្សារៀនសូត្រជំនាញការងារពាក់ព័ន្ធ ដើម្បីពង្រឹងសមត្ថភាពបន្ថែម ពីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មន្ទីរអង្គភាព ស្ថាប័នជំនាញ និងពីអង្គការដៃគូនានា ដើម្បីប្រសិទ្ធភាពការងារ

- ធ្វើរបាយការណ៍ការងារប្រចាំថ្ងៃ ដាក់ជូនអ្នកគ្រប់គ្រងមណ្ឌល និងបញ្ជូនទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមប្រព័ន្ធព័ត៌មានវិទ្យា
- ខិតខំស្វែងយល់ និងចូលរួមវគ្គសិក្សានានា ដែលជាការអភិវឌ្ឍខ្លួនក្នុងវិស័យដែលខ្លួនទទួលខុសត្រូវ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការណែនាំ និងចាត់ចែងរបស់ប្រធាន ។

៤. បុគ្គលិកមណ្ឌល មានភារកិច្ច៖

- ជួយផ្នែកអនាម័យ ថែសួន ការងារថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹក ភ្លើង ការងារដឹកជញ្ជូន លើកដាក់សម្ភារ
- ជួយផ្នែកការងារសន្តិសុខ សណ្តាប់ធ្នាប់ ពិនិត្យរបៀបរៀបរយអ្នកចេញចូល ការពារសន្តិសុខ កន្លែងចតយានយន្ត ណែនាំអប់រំអ្នកប្រព្រឹត្តខុសឆ្គង រំខាន ឱ្យគោរពវិន័យបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល។

មន្ត្រីដែលបម្រើការងារក្នុងមណ្ឌល គឺស្ថិតក្រោមខ្សែបណ្តោយរបស់មន្ទីរអង្គភាពពាក់ព័ន្ធ និងជាមន្ត្រីដែលទទួលការចាត់តាំងពីរដ្ឋបាលស្រុកកំរៀង ខេត្តបាត់ដំបង ដើម្បីទទួលបន្ទុកគ្រប់គ្រង និងអនុវត្តការងារប្រចាំថ្ងៃ។

បុគ្គលិកមណ្ឌល ជាបុគ្គលិកជាប់កិច្ចសន្យា ដែលត្រូវបានជ្រើសរើសដោយរដ្ឋបាលស្រុកកំរៀង ខេត្តបាត់ដំបង យោងតាមតម្រូវការចាំបាច់នៃការងារ ។

ប្រការ ៦._

- មណ្ឌលទទួលពលករកំរៀង មានប្រភពធនធានផ្តត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកា នៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ការគ្រប់គ្រង និងចាត់ចែងចំណូល-ចំណាយ ត្រូវអនុវត្តតាមនីតិវិធីនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- មណ្ឌលទទួលពលករកំរៀង មានសិទ្ធិទទួលគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ ជាធរមាននូវមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍ និងប្រភពផ្សេងៗទៀត ដើម្បីជានាការអនុវត្តដំណើរការការងាររបស់ខ្លួន ។

**ប្រការ ៧.**_

- ប្រធាន និងអ្នកគ្រប់គ្រងមណ្ឌលទទួលពលករកំរៀង ត្រូវបែងចែកមន្ត្រីក្រោមឱវាទ ដើម្បីទទួលខុសត្រូវ និងបំពេញការងារ ។
- លេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តបាត់ដំបង មន្ទីរអង្គភាពពាក់ព័ន្ធត្រូវទទួលខុសត្រូវ និងផ្តល់សេវាតាមជំនាញពាក់ព័ន្ធរៀងៗខ្លួន ។

**ប្រការ ៨.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.**_

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តបាត់ដំបង រដ្ឋបាលស្រុកកំរៀង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ

សម្បទាខេត្តបាត់ដំបង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង អង្គភាពពាក់ព័ន្ធ និងសមាសភាព ដូចមានចែងក្នុងប្រការ៣ និងប្រការ៥ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ១៣កើត ខែ ទុតិយាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល៖
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង-ស្ថាប័ន សមាជិក គ.ជ.ប.ជ
- រដ្ឋបាលខេត្តបាត់ដំបង
- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបាត់ដំបង
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥
  "ដើម្បីអនុវត្ត"
- ឯកសារ -កាលប្បវត្តិ

# បុគ្គលិកមណ្ឌលទទួលពលករកំរៀង



# សកម្មភាព














KAMRIENG MIGRANT RECEPTION CENTRE ( Battambang )


CARITAS